អាជ្ញាធរអគ្គិសនីកម្ពុជា
លេខ១០០.សណា.២៥.អអក

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ថ្ងៃ អង្គារ ៩រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គេហទំព័រច្រកចេញចូលតែមួយ (Web Portal) សម្រាប់ការបំពេញបែបបទស្នើសុំដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា

អាជ្ញាធរអគ្គិសនីកម្ពុជា មានកិត្តិយសសូមគោរពទូលថ្វាយ និងជម្រាបជូនសម្តេច ទ្រង់ ឯកឧត្តម/លោកជំទាវ លោកអ្នកឧកញ៉ា/អ្នកឧកញ៉ា/ឧកញ៉ា លោក/លោកស្រី/នាងកញ្ញា និងសាធារណជនទូទៅ មេត្តាជ្រាបថា ក្នុងក្របខណ្ឌនៃបទប្បញ្ញត្តិស្តីពីការដំឡើង និងការប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលនៅកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាបានរៀបចំរួចរាល់នូវគេហទំព័រច្រកចេញចូលតែមួយ (Web Portal) សម្រាប់សាធារណជនទូទៅដែលមានបំណងដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល អាចទទួលបានព័ត៌មាន ឯកសារពាក់ព័ន្ធនានា និងអាចបំពេញបែបបទស្នើសុំដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូលតាមរយៈអនឡាញ។ ដូច្នេះ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ការបំពេញបែបបទស្នើសុំដំឡើង និងប្រើប្រាស់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យលើដំបូល ត្រូវអនុវត្តតាមប្រព័ន្ធឌីជីថល គឺតាមគេហទំព័រច្រកចេញចូលតែមួយ ដែលមានអាសយដ្ឋាន rts.eac.gov.kh ឬ QR កូដដូចមានភ្ជាប់មកជាមួយ។

សេចក្តីដូចបានគោរពទូលថ្វាយ និងជម្រាបជូនខាងលើ សូមសម្តេច ទ្រង់ ឯកឧត្តម/លោកជំទាវ លោកអ្នកឧកញ៉ា/អ្នកឧកញ៉ា/ឧកញ៉ា លោក/លោកស្រី/នាងកញ្ញា និងសាធារណជនទូទៅ មេត្តាជ្រាបជាព័ត៌មាន។

អាជ្ញាធរអគ្គិសនីកម្ពុជា
ប្រធាន

យឹម ទិសិដ្ឋ

ចម្លងជូន
- ក្រសួងរ៉ែ និងថាមពល
- អគ្គិសនីកម្ពុជា
- ឯកសារ-កាលប្បវត្តិ

rts.eac.gov.kh